| ៧- | លោក | ជា ផាង | សប្បុរសជន នៅខេត្តកំពង់ធំ |
| ៨- | លោក | ឱម សុផល | សប្បុរសជន នៅខេត្តកំពង់ធំ |
| ៩- | លោក | ឃួន វណ្ណារិទ្ធ | សប្បុរសជន នៅខេត្តកំពង់ធំ |
| ១០- | លោក | គង់ អាន់ | សប្បុរសជន នៅខេត្តកំពង់ធំ |

**គ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សប្ញទ្ធិ**

| | | | |
|---|---|---|---|
| ១- | ឧបាសក | ដួង សឿង | សប្បុរសជន នៅខេត្តកំពង់ធំ |
| ២- | ឧបាសក | គូ ស៊ុនហោ | សប្បុរសជន នៅខេត្តកំពង់ធំ |
| ៣- | ឧបាសិកា | ឱត ចេង | សប្បុរសជន នៅខេត្តកំពង់ធំ |
| ៤- | លោក | ហម ឆាយាត | សប្បុរសជន នៅខេត្តកំពង់ធំ |

| | | | |
|---|---|---|---|
| ៥- | លោក | **ចាន់ គឿន** | សប្បុរសជន នៅខេត្តកំពង់ធំ |
| ៦- | លោក | **ឧត គីមណារិទ្ធ** | សប្បុរសជន នៅស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ |
| ៧- | វរសេនីយ៍ឯក | **ស៊ិន លិញ** | សប្បុរសជន នៅស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ |
| ៨- | វរសេនីយ៍ឯក | **ឆាម ឆេងគ្រី** | សប្បុរសជន នៅស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ |
| ៩- | វរសេនីយ៍ឯក | **ផន ផាត** | សប្បុរសជន នៅស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ |
| ១០- | វរសេនីយ៍ឯក | **ស៊ឹម ចាន់ថន** | សប្បុរសជន នៅស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ |
| ១១- | វរសេនីយ៍ឯក | **សម ចំណាប់** | សប្បុរសជន នៅស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ |
| ១២- | វរសេនីយ៍ឯក | **លៀង កែវ** | សប្បុរសជន នៅស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ |
| ១៣- | វរសេនីយ៍ត្រី | **យន់ នៃយ៉ាន** | សប្បុរសជន នៅស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ |

**មាត្រា ២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង និងកំពង់ធំ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៧ ខែ កក្កដា ឆ្នាំ ២០១៧*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៥៥០ ....សហវ.ប្រក

# ប្រកាស

## ស្តីពី

## ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ សម្រាប់ឆ្នាំ២០១៧

## ទេសរដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០១៩៨/០១ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៨
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៣/០១៥ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- បានឃើញក្រឹត្យលេខ ២៤/ក្រ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៩១ ដែលប្រកាសឱ្យប្រើច្បាប់ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ១៩៩១ ស្តីពីការបង្កើតពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ
- បានឃើញអនុក្រឹត្យលេខ ០៨/អនក្រ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៩១ ស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមការចាំបាច់ក្នុងការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៧

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92,Sangkat Wat Phnom , Khan Daun Penh, Phnom Penh, COMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798

## សម្រេច

**ប្រការ ១.-**

ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៧ ត្រូវប្រមូលចាប់ពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ រហូតដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧។

**ប្រការ ២.-**

ម្ចាស់មធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ ត្រូវបង់ប្រាក់ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៧ នៅតាមសាខាពន្ធដារខេត្ត-ខណ្ឌ ឬនៅធនាគារ កាណាឌីយ៉ា ក.អ ឬនៅធនាគារ អេស៊ីលីដា ភីអិលស៊ី ឬនៅធនាគារ កម្ពុជាសាធារណៈ ភីអិលស៊ី ឬនៅធនាគារ វឌ្ឍនៈ ឬនៅធនាគារ អេ អ៊ិន ហ្សេត រ៉ូយ៉ាល់។

**ប្រការ ៣.-**

ដើម្បីបង់ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៧ ម្ចាស់យានយន្តត្រូវភ្ជាប់មកជាមួយនូវ ÷

**ក. ចំពោះម្ចាស់យានយន្តដែលមានប័ណ្ណសម្គាល់ការបង់ពន្ធប្រភេទនេះ ÷**

- ប័ណ្ណសម្គាល់ការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ ដោយមិនចាំបាច់ដាក់លិខិតប្រកាសបង់ពន្ធ
- ករណីបាត់ប័ណ្ណនេះ ម្ចាស់យានយន្តត្រូវដាក់ពាក្យស្នើសុំបោះពុម្ពប័ណ្ណបង់ពន្ធសាជាថ្មីនៅសាខាពន្ធដារខេត្ត-ខណ្ឌ ឬនៅសាខាណាមួយនៃធនាគារទាំងប្រាំខាងលើ ដោយត្រូវបង់កម្រៃសេវាក្នុងការធ្វើប័ណ្ណនេះចំនួន ៥ ០០០ រៀល។

**ខ. ចំពោះម្ចាស់យានយន្តដែលមិនមានប័ណ្ណសម្គាល់ការបង់ពន្ធប្រភេទនេះ ÷**

- ត្រូវបំពេញ និងដាក់លិខិតប្រកាសបង់ពន្ធចំនួន ០២សន្លឹក តាមទម្រង់ដែលចេញដោយអគ្គនាយកដ្ឋានពន្ធដារ ដោយភ្ជាប់មកជាមួយឯកសារបង់ពន្ធឆ្នាំ២០១៦
- ករណីបាត់ឯកសារបង់ពន្ធនេះ ម្ចាស់យានយន្តត្រូវដាក់ពាក្យស្នើសុំលិខិតបញ្ជាក់ការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៦ នៅសាខាពន្ធដារខេត្ត-ខណ្ឌ ដើម្បីប្រើប្រាស់ក្នុងការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៧។

**គ. ចំពោះមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ដែលទើបមកប្រកាសបង់ពន្ធលើកដំបូង ÷**

ត្រូវបំពេញ និងដាក់លិខិតប្រកាសបង់ពន្ធចំនួន ០២សន្លឹក តាមទម្រង់ដែលចេញដោយអគ្គនាយកដ្ឋានពន្ធដារ និងភ្ជាប់មកជាមួយនូវឯកសារ ដូចមានចែងខាងក្រោម ÷

- ប័ណ្ណសម្គាល់យានយន្ត ឬ
- វិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត ដែលចេញដោយក្រសួងសាធារណការនិងដឹកជញ្ជូន ឬ
- បង្កាន់ដៃបង់ពន្ធនាំចូល ឬ
- លិខិតបញ្ជាក់ការប្រើប្រាស់យានយន្តចេញដោយឃុំ-សង្កាត់ ចំពោះយានយន្តកែច្នៃក្នុងស្រុក និង
- អត្តសញ្ញាណប័ណ្ណសម្គាល់ខ្លួនរបស់ម្ចាស់មធ្យោបាយដឹកជញ្ជូននិងយានជំនិះ ឬលិខិតឆ្លងដែន ឬលិខិតបញ្ជាក់សំបុត្រកំណើតចេញដោយមន្ត្រីអត្រានុកូលដ្ឋាន។

**ឃ. ចំពោះមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ ដែលបានបង់ពន្ធឆ្នាំកន្លងមក ហើយត្រូវបានប្តូរប័ណ្ណសម្គាល់យានយន្តថ្មី ៖**

- ម្ចាស់យានយន្តត្រូវធ្វើបច្ចុប្បន្នភាពព័ត៌មានយានយន្ត ដើម្បីប្រកាសបង់ពន្ធបន្ត និង
- ប្តូរប័ណ្ណសម្គាល់ការបង់ពន្ធក្នុងករណីរថយន្តនោះត្រូវបានប្តូរស្លាកលេខ។

ដើម្បីមានភាពងាយស្រួលក្នុងការប្រកាសបង់ពន្ធប្រភេទនេះនៅឆ្នាំបន្តបន្ទាប់ខាងមុខ ម្ចាស់យានជំនិះអាចស្នើសុំធ្វើប័ណ្ណសម្គាល់ការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ ដោយគ្រាន់តែគូសក្នុងប្រអប់ដូចមានបង្ហាញក្នុងលិខិតប្រកាសបង់ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៧។ ការស្នើសុំបោះពុម្ពប័ណ្ណនេះត្រូវបង់ថ្លៃសេវាចំនួន ៥ ០០០ រៀល។

**ប្រការ ៤.-**

មធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ ដែលខកខាន ឬមិនបានបង់ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទសម្រាប់បណ្តាឆ្នាំកន្លងមក ត្រូវបង់ប្រាក់ពន្ធ និងប្រាក់ពិន័យឱ្យបានរួចរាល់ជាមុនសិន ទើបអនុញ្ញាតឱ្យប្រកាសបង់ពន្ធសម្រាប់ឆ្នាំ២០១៧។

ចំពោះមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទទាំងឡាយណា ដែលមានបង្កាន់ដៃបង់ពន្ធនាំចូលចាប់ពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៦ ត្រូវបានអនុញ្ញាតឱ្យបង់ពន្ធសម្រាប់ឆ្នាំ២០១៧។ ការអនុញ្ញាតនេះមិនមានអានុភាពប្រតិសកម្មចំពោះប្រាក់ពន្ធដែលបានបង់រួចហើយនោះទេ។

ចំពោះមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទទាំងឡាយណា ដែលមានបង្កាន់ដៃបង់ពន្ធនាំចូលចាប់ពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៧ ជាកម្មវត្ថុសម្រាប់ការប្រកាសបង់ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទនៅឆ្នាំបន្ទាប់។

ការអនុញ្ញាតឱ្យប្រកាសបង់ពន្ធក្នុងកថាខណ្ឌ២ និងកថាខណ្ឌ៣ ខាងលើនេះ គឺទទួលស្គាល់តែកាលបរិច្ឆេទនៃបង្កាន់ដៃបង់ពន្ធនាំចូលតែប៉ុណ្ណោះ។

**ប្រការ ៥.-**

ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ ត្រូវកំណត់ទៅតាមប្រភេទនីមួយៗ ដោយមិនគិតថាជាកម្មសិទ្ធិរបស់រដ្ឋ ឬឯកជនឡើយ ដូចមានចែងក្នុងឧបសម្ព័ន្ធភ្ជាប់ជាមួយប្រកាសនេះ ៖

- ឧបសម្ព័ន្ធI ស្តីពីការកំណត់ប្រាក់ពន្ធតាមប្រភេទមធ្យោបាយដឹកជញ្ជូន ក្រៅពីរថយន្តទេសចរណ៍ និង
- ឧបសម្ព័ន្ធII ស្តីពីការកំណត់ប្រាក់ពន្ធតាមទំហំស៊ីឡាំងរបស់រថយន្តទេសចរណ៍។

**ប្រការ ៦.-**

ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ ត្រូវបានលើកលែងចំពោះ ៖

- រថយន្តគិលានសង្គ្រោះ រថយន្តពន្លត់អគ្គិភ័យជាកម្មសិទ្ធិរបស់រដ្ឋ
- យានយន្តដែលជាកម្មសិទ្ធិរបស់អង្គភាពកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ នគរបាលជាតិ ដែលបម្រើការងារសម្រាប់កិច្ចការការពារជាតិ ជាមធ្យោបាយប្រើប្រាស់ដឹកជញ្ជូនសម្ភារទ័ព ឬដឹកជញ្ជូនកងទ័ព ក៏ដូចជាសម្រាប់កិច្ចការសន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ដូចមានចែងក្នុងមាត្រា ១១ និងមាត្រា ១២ នៃអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្តីពីការចេញផ្លាកលេខសម្គាល់យានជំនិះ និងយានយន្តដែលពាក់ផ្លាកលេខ ខ.ម ឬ ន.ប ជាផ្លូវការ ដែលមានការទទួលស្គាល់ និងបញ្ជាក់ពីក្រសួងការពារជាតិ ឬក្រសួងមហាផ្ទៃ

- យានយន្តដែលជាកម្មសិទ្ធិរបស់ស្ថានទូត ឬស្ថានកុងស៊ុលបរទេស អង្គការអន្តរជាតិ ឬទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា។

ក្រសួង-ស្ថាប័ន ឬអង្គភាព ដែលជាអាណាព្យាបាល ឬជាម្ចាស់កម្មសិទ្ធិនៃយានយន្តដូចមានចែងនៅក្នុងប្រការនេះ ត្រូវស្នើសុំមកអគ្គនាយកដ្ឋានពន្ធដារ ដើម្បីទទួលបាននូវលតាបត្របង់ពន្ធ (ពន្ធជាបន្ទុករបស់រដ្ឋ) ដោយភ្ជាប់មកជាមួយនូវបញ្ជីសារពើភណ្ឌយានយន្តរបស់ក្រសួង-ស្ថាប័ន ឬអង្គភាពដែលបានស្នើសុំនោះ។

**ប្រការ ៧.-**

ក្រោយពេលបង់ពន្ធរួចហើយ ម្ចាស់មធ្យោបាយដឹកជញ្ជូននិងយានជំនិះ ត្រូវទទួលបានបង្កាន់ដៃទទួលប្រាក់ពន្ធមួយសន្លឹកចេញពីប្រព័ន្ធគ្រប់គ្រងរបស់អគ្គនាយកដ្ឋានពន្ធដារ និងលតាបត្រសម្រាប់បិទភ្ជាប់មធ្យោបាយដឹកជញ្ជូននិងយានជំនិះមួយសន្លឹក។ បង្កាន់ដៃទទួលប្រាក់ពន្ធនេះ ត្រូវរក្សាទុកជាប់នឹងយានយន្តសម្រាប់បង្ហាញមន្ត្រីមានសមត្ថកិច្ច និងជាឯកសារសម្រាប់ប្រកាសបង់ពន្ធនៅឆ្នាំបន្ទាប់។

**ប្រការ ៨.-**

សម្រាប់ឆ្នាំ២០១៧ លតាបត្របង់ពន្ធដែលត្រូវបិទភ្ជាប់នឹងយានយន្ត ត្រូវបានកំណត់ប្រាក់ពន្ធទៅតាមប្រភេទយានយន្តនីមួយៗ ដែលមានរូបភាព មានលក្ខណៈសម្គាល់ និងទម្រង់តែមួយប្រភេទ ហើយដែលអាចធានាបាននូវគុណភាពជាប់ស្អិតរហូតរយៈពេល១ឆ្នាំ។ ក្នុងករណីមានការរបក ឬបិទមិនជាប់ម្ចាស់យានយន្តអាចស្នើសុំប្តូរយកលតាបត្រថ្មីបាននៅតាមសាខាពន្ធដារខេត្ត-ខណ្ឌ។

**ប្រការ ៩.-**

ត្រូវបានកែសម្រួលយថាប្រភេទមធ្យោបាយដឹកជញ្ជូនមួយចំនួន ÷

**ក. ចាត់ជារថយន្តទេសចរណ៍ ÷**

- រថយន្តដឹកទំនិញធុនតូចដែលមានទ្វារ៤ (PICK UP) ត្រូវបានចាត់ទុកជារថយន្តទេសចរណ៍ចំពោះរថយន្ត មានអាយុកាលគិតពីឆ្នាំផលិតដល់ ០៥ឆ្នាំ ត្រូវបង់ពន្ធតាមទំហំស៊ីឡាំង ដូចមានចែងក្នុងឧបសម្ព័ន្ធ II ភ្ជាប់ជាមួយប្រកាសនេះ និងត្រូវបានចាត់ទុកជារថយន្តដឹកទំនិញធុនតូច មានទម្ងន់សរុបដល់ ៣តោន នៅពេលដែលរថយន្តនេះមានអាយុកាលគិតពីឆ្នាំផលិតលើសពី ០៥ឆ្នាំ ត្រូវបង់ពន្ធតាមទម្ងន់ផ្ទុក ដូចមានចែងក្នុងឧបសម្ព័ន្ធ I
- រថយន្តដឹកអ្នកដំណើរ ត្រូវបានចាត់ទុកជារថយន្តទេសចរណ៍ចំពោះរថយន្តមានអាយុកាលគិតពីឆ្នាំផលិតដល់ ០៥ឆ្នាំ ត្រូវបង់ពន្ធតាមទំហំស៊ីឡាំង ដូចមានចែងក្នុងឧបសម្ព័ន្ធ II ភ្ជាប់ជាមួយប្រកាសនេះ និងត្រូវបានចាត់ទុកជារថយន្តដឹកអ្នកដំណើរ នៅពេលដែលរថយន្តនេះមានអាយុកាលគិតពីឆ្នាំផលិតលើសពី ០៥ឆ្នាំ ត្រូវបង់ពន្ធតាមចំនួនកៅអី ដូចមានចែងក្នុងឧបសម្ព័ន្ធ I។

**ខ.** ចាត់ជារថយន្តដឹកទំនិញចំពោះក្បាលរថយន្តសណ្តោង និងសីមីរ៉ឺម៉ក ត្រូវបានបង់ពន្ធរួមគ្នាគិតទាំងទម្ងន់ក្បាលរថយន្តសណ្តោង ទម្ងន់សីមីរ៉ឺម៉ក និងទម្ងន់ផ្ទុក មាន ÷

+ ក្បាលរថយន្តសណ្តោងសំដៅដល់រថយន្តសម្រាប់សណ្តោងសីមីរ៉ឺម៉ក
+ សីមីរ៉ឺម៉កសំដៅដល់យានសម្រាប់ផ្ទុកជាប់នឹងក្បាលរថយន្តសណ្តោង

ករណីនេះ ចាត់ទុកជារថយន្តដឹកទំនិញធុនធ្ងន់ ហើយប្រាក់ពន្ធត្រូវបង់មានចំនួន ២ ០០០ ០០០ រៀល។

ករណីកើតមានរ៉ឺម៉កសណ្ដោងបន្ថែមទៀត រ៉ឺម៉កសណ្ដោងនោះត្រូវបង់ពន្ធដោយឡែកតាមទម្ងន់ផ្ទុក ឬតាមចំនួនភ្លៅ និងចំនួនកង់។

**គ.** ចំពោះរថយន្តកែច្នៃ ត្រូវកំណត់ដោយផ្អែកតាមទម្ងន់សរុប រួមមាន ទម្ងន់រថយន្ត និងទម្ងន់ផ្ទុក (ទំនិញ-មនុស្ស) ឬចំនួនភ្លៅ និងចំនួនកង់ ដូចមានចែងក្នុងឧបសម្ព័ន្ធ I។

**ឃ.** ចំពោះរ៉ឺម៉កសណ្ដោងកែច្នៃ ត្រូវកំណត់ដោយផ្អែកតាមទម្ងន់សរុប រួមមាន ទម្ងន់រ៉ឺម៉កសណ្ដោង និងទម្ងន់ផ្ទុក (ទំនិញ) ឬចំនួនភ្លៅ និងចំនួនកង់ ដូចមានចែងក្នុងឧបសម្ព័ន្ធ I។

**ប្រការ ១០.-**

ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ តទៅ អគ្គនាយកដ្ឋានពន្ធដារត្រូវរៀបចំយន្តការត្រួតពិនិត្យការបង់ពន្ធ និងដាក់ពិន័យចំពោះមធ្យោបាយដឹកជញ្ជូននិងយានជំនិះទាំងឡាយណា ដែលមិនបានប្រកាសបង់ពន្ធតាមការកំណត់ខាងលើ។

**ប្រការ ១១.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកនៃអគ្គនាយកដ្ឋាននានាចំណុះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៧

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**<u>កន្លែងទទួល</u>** ÷

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង - ស្ថាប័ន
- គ្រប់អង្គភាពក្រោមឱវាទ កសហវ "ដើម្បីអនុវត្ត"
- គ្រប់សាលារាជធានី - ខេត្ត "ដើម្បីសហការអនុវត្ត"
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ....................សហវ

## ឧបសម្ព័ន្ធ I

### ស្តីពី

### ការកំណត់ប្រាក់ពន្ធតាមប្រភេទមធ្យោបាយដឹកជញ្ជូន ក្រៅពីរថយន្តទេសចរណ៍

ភ្ជាប់ជាមួយប្រកាសលេខ[illegible] សហវ.ប្រក ចុះថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០១៧ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ក. មធ្យោបាយដឹកជញ្ជូនទូទៅ ÷**

ឯកតា÷ រៀល

| ប្រភេទមធ្យោបាយដឹកជញ្ជូន និងយានជំនិះ | កម្រិតប្រាក់ពន្ធ សម្រាប់១ឆ្នាំ/គ្រឿង |
|---|---|
| **១. រថយន្តដឹកទំនិញមានទម្ងន់សរុប [ទម្ងន់រថយន្ត និងទម្ងន់ផ្ទុក (ទំនិញ និងមនុស្ស)] ÷** | |
| - ដល់ ៣តោន | ២០០ ០០០ |
| - លើសពី ៣តោន ដល់ ១០តោន | ៥០០ ០០០ |
| - លើសពី ១០តោន ដល់ ២០តោន | ១ ០០០ ០០០ |
| - លើសពី ២០តោន | ២ ០០០ ០០០ |
| **២. រ៉ឺម៉កសណ្តោងដែលមានទម្ងន់សរុប (ទម្ងន់រ៉ឺម៉ក និងទម្ងន់ផ្ទុក) ÷** | |
| - ចាប់ពី ៣តោន ដល់ ១០តោន | ៥០០ ០០០ |
| - លើសពី ១០តោន ដល់ ២០តោន | ១ ០០០ ០០០ |
| - លើសពី ២០តោន | ២ ០០០ ០០០ |
| **៣. រថយន្តដឹកអ្នកដំណើរ ÷** | |
| - រថយន្តដឹកអ្នកដំណើរមានកៅអីដល់ ១៥កៅអី | ១៥០ ០០០ |
| - រថយន្តដឹកអ្នកដំណើរចុះមធ្យម មានកៅអីពី ១៦កៅអី ដល់ ២៥កៅអី | ២០០ ០០០ |
| - រថយន្តដឹកអ្នកដំណើរចុះធំ មានកៅអីលើសពី ២៥កៅអី | ២៥០ ០០០ |
| **៤. ជលយាន ឬជលយានយន្ត ផ្លូវទន្លេ ÷** | |
| **- ជលយាន ឬជលយានយន្តដឹកទំនិញ ÷** | |
| + ដល់ ៣តោន | ៥០ ០០០ |
| + លើសពី ៣តោន ដល់ ១០តោន | ១០០ ០០០ |
| + លើសពី ១០តោន ដល់ ២០តោន | ២០០ ០០០ |
| + លើសពី ២០តោន | ៣០០ ០០០ |

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92,Sangkat Wat Phnom , Khan Daun Penh, Phnom Penh, COMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798

| | |
|---|---|
| **- ជលយាន ឬជលយានយន្តដឹកអ្នកដំណើរ ÷** | |
| + កប៉ាល់មានបណ្តោយដល់ ២០ម៉ែត្រ | ១០០ ០០០ |
| + កប៉ាល់មានបណ្តោយលើសពី ២០ម៉ែត្រ ដល់ ៣០ម៉ែត្រ | ២០០ ០០០ |
| + កប៉ាល់មានបណ្តោយលើសពី ៣០ម៉ែត្រ ឡើងទៅ | ៣០០ ០០០ |
| **- ជលយាន ឬជលយានយន្តសណ្តោង ÷** | |
| + កប៉ាល់មានកម្លាំងលើសពី ១៥០សេះ ដល់ ២០០សេះ | ៦០ ០០០ |
| + កប៉ាល់មានកម្លាំងលើសពី ២០០សេះ ដល់ ២៥០សេះ | ១៨០ ០០០ |
| + កប៉ាល់មានកម្លាំងលើសពី ២៥០សេះ ឡើងទៅ | ៣០០ ០០០ |
| **- ជលយាន ឬជលយានយន្តនេសាទ ÷** | |
| + កាណូតមានកម្លាំងលើសពី ១៥០សេះ ដល់ ២០០សេះ | ៦០ ០០០ |
| + កាណូតមានកម្លាំងលើសពី ២០០សេះ ដល់ ២៥០សេះ | ១៨០ ០០០ |
| + កាណូតមានកម្លាំងលើសពី ២៥០សេះ ឡើងទៅ | ៣០០ ០០០ |
| **៥. ជលយាន ឬជលយានយន្ត ផ្លូវសមុទ្រ ÷** | |
| **- ជលយាន ឬជលយានយន្តដឹកអ្នកដំណើរ ÷** | |
| + ទូកមានបណ្តោយដល់ ២០ម៉ែត្រ | ១០០ ០០០ |
| + ទូកមានបណ្តោយពី ២១ម៉ែត្រ ដល់ ៣០ម៉ែត្រ | ១៥០ ០០០ |
| **- ជលយាន ឬជលយានយន្តដឹកទំនិញ ÷** | |
| + ទូកផ្ទុកទំនិញដល់ ១០០តោន | ២០០ ០០០ |
| + កប៉ាល់ផ្ទុកទំនិញលើសពី ១០០តោន ដល់ ១ ០០០តោន | ៣០០ ០០០ |
| + កប៉ាល់ផ្ទុកទំនិញលើសពី ១ ០០០តោន ដល់ ២ ០០០តោន | ៧៥០ ០០០ |
| + កប៉ាល់ផ្ទុកទំនិញលើសពី ២ ០០០តោន ឡើងទៅ | ១ ២០០ ០០០ |
| **- ជលយាន ឬជលយានយន្តនេសាទ ÷** | |
| + ទូកមានកម្លាំងលើសពី ១៥០សេះ ឡើងទៅ | ១០០ ០០០ |
| + កប៉ាល់មានកម្លាំងលើស ១៥០សេះ | ៣០០ ០០០ |
| + កប៉ាល់មានកម្លាំងលើសពី ១៥០សេះ ដល់ ២៥០សេះ | ៤០០ ០០០ |
| + កប៉ាល់កម្លាំងលើសពី ២៥០សេះ ដល់ ៥០០សេះ | ៦០០ ០០០ |
| + កប៉ាល់មានកម្លាំងលើសពី ៥០០សេះ ឡើងទៅ | ១ ២០០ ០០០ |
| **- ជលយាន ឬជលយានយន្តសណ្តោង ÷** | |
| + កប៉ាល់មានកម្លាំងដល់ ២៥០សេះ | ២០០ ០០០ |
| + កប៉ាល់មានកម្លាំងលើសពី ២៥០សេះ ដល់ ៥០០សេះ | ៤០០ ០០០ |
| + កប៉ាល់មានកម្លាំងលើសពី ៥០០សេះ ឡើងទៅ | ៦០០ ០០០ |
| **៦. អ្នូប៉រផ្លូវទន្លេ/សមុទ្រ ÷** | |
| - មានកម្លាំងលើសពី ១៥០សេះ ដល់ ២០០សេះ | ៤០០ ០០០ |
| - មានកម្លាំងលើសពី ២០០សេះ ឡើងទៅ | ៥០០ ០០០ |

**ខ. មធ្យោបាយដឹកជញ្ជូនកែច្នៃផ្សេងទៀត ÷**

ឯកតា÷ រៀល

| **ប្រភេទមធ្យោបាយដឹកជញ្ជូន និងយានជំនិះ** | **កម្រិតប្រាក់ពន្ធ សម្រាប់១ឆ្នាំ/គ្រឿង** |
|---|---|
| ១. រថយន្តដែលបំប្លែងមកពីគោយន្ត និងរថយន្តកែច្នៃកង់បី (បំពាក់ដោយម៉ាស៊ីនរថយន្ត) ត្រូវកំណត់ជារថយន្តដឹកទំនិញដល់ ៣តោន | ២០០ ០០០ |
| ២. រ៉ឺម៉កសណ្តោងដែលមានភ្លៅ២ កង់៤ (ចាត់ទុកដូចរថយន្តកែច្នៃខាងលើដែរ) | ២០០ ០០០ |
| ៣. រ៉ឺម៉កសណ្តោងដែលមានភ្លៅ២ កង់៨ | ៥០០ ០០០ |
| ៤. រថយន្តដឹកទំនិញដែលមានភ្លៅ៣ កង់៦ | ១ ០០០ ០០០ |
| ៥. រថយន្តដឹកទំនិញធុនធ្ងន់ដែលមានភ្លៅ៣ កង់១០ | ២ ០០០ ០០០ |

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

MINISTRY OF ECONOMY AND FINANCE

លេខ...................សហវ

# ឧបសម្ព័ន្ធ II
## ស្តីពី
## ការកំណត់ប្រាក់ពន្ធតាមទំហំស៊ីឡាំងរបស់រថយន្តទេសចរណ៍

ភ្ជាប់ជាមួយប្រកាសលេខ [illegible] ប្រក.សហវ.អពដ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ឯកតា ÷ រៀល

| ល.រ | ទំហំស៊ីឡាំងគិតជា ស.ម³ "CC" | គិតពីឆ្នាំផលិត | | |
|---|---|---|---|---|
| | | ដល់ ៥ឆ្នាំ | លើសពី៥ឆ្នាំ ដល់១០ឆ្នាំ | លើសពី ១០ឆ្នាំ |
| ១ | ដល់ ១ ៥០០ស.ម³ | ១៥០ ០០០ | ១០០ ០០០ | ៨០ ០០០ |
| ២ | លើសពី ១ ៥០០ស.ម³ ដល់ ២ ០០០ស.ម³ | ២០០ ០០០ | ១៥០ ០០០ | ១០០ ០០០ |
| ៣ | លើសពី ២ ០០០ស.ម³ ដល់ ២ ៩០០ស.ម³ | ៦០០ ០០០ | ៤០០ ០០០ | ២៥០ ០០០ |
| ៤ | លើសពី ២ ៩០០ស.ម³ ដល់ ៤ ០០០ស.ម³ | ១ ៦០០ ០០០ | ១ ០០០ ០០០ | ៦០០ ០០០ |
| ៥ | លើសពី ៤ ០០០ស.ម³ ឡើងទៅ | ២ ០០០ ០០០ | ១ ២០០ ០០០ | ៨០០ ០០០ |

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ តុលា ឆ្នាំ២០១៧

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៥៥៩........សហវ.ឫប.ក.

# ប្រកាស

## ស្តីពី

## ការណែនាំអនុវត្តអាករលើតម្លៃបន្ថែមចំពោះការផ្គត់ផ្គង់មិនជាប់អាករ

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៦/០១៩ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីអាករលើតម្លៃបន្ថែម
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.

ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## សម្រេច

**ប្រការ ១.- គោលបំណង**

ប្រកាសនេះ មានគោលបំណងណែនាំអនុវត្តអាករលើតម្លៃបន្ថែមចំពោះការផ្គត់ផ្គង់មិនជាប់អាករ ស្របតាមមាត្រា៥៧ នៃច្បាប់ស្តីពីសារពើពន្ធ ដែលត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧។

**ប្រការ ២.- គោលដៅ**

ប្រកាសនេះ មានគោលដៅកំណត់ឱ្យបានច្បាស់លាស់នូវទំនិញឬសេវាមួយចំនួន ដែលជាកម្មវត្ថុនៃការផ្គត់ផ្គង់មិនជាប់អាករ ដូចមានចែងក្នុងមាត្រា៥៧ នៃច្បាប់ស្តីពីសារពើពន្ធ សំដៅធានាបាននូវសង្គតិភាពក្នុងការអនុវត្តអាករលើតម្លៃបន្ថែម ដើម្បីជំរុញសកម្មភាពសេដ្ឋកិច្ច និងកាត់បន្ថយបន្ទុកចំណាយរបស់ប្រជាពលរដ្ឋលើការប្រើប្រាស់ទំនិញឬសេវាចាំបាច់មួយចំនួន ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។

**ប្រការ ៣.- វិសាលភាព**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសដែលធ្វើការផ្គត់ផ្គង់មិនជាប់អាករ។

**ប្រការ ៤.- និយមន័យ**

សម្រាប់គោលដៅនៃប្រកាសនេះ÷

១- ពាក្យ "អាករ" សំដៅដល់ អាករលើតម្លៃបន្ថែម។

២- ពាក្យ "សេវាជាមូលដ្ឋានខាងហិរញ្ញវត្ថុ" សំដៅដល់ សេវាខាងហិរញ្ញវត្ថុដែលទាញយកកម្រិតប្រាក់លម្អៀងជាប្រាក់ចំណេញ ជាអាទិ៍មាន÷

- ក- ប្រតិបត្តិការទទួលប្រាក់បញ្ញើ ផ្តល់ឥណទានឬឱ្យខ្ចីបុល ប៉ុន្តែមិនរួមបញ្ចូលកម្រៃសេវាដែលទាក់ទិននឹងការផ្តល់ឥណទានឬខ្ចីបុល
- ខ- ការបោះផ្សាយលក់មូលបត្រក្នុងទីផ្សារដំបូង ការជួញដូរមូលបត្រឬឧបករណ៍ហិរញ្ញវត្ថុដទៃទៀត និងសេវាជាត់ទាត់និងទូទាត់ក្នុងទីផ្សារមូលបត្រកម្ពុជា
- គ- សេវាប្តូរប្រាក់
- ឃ- សេវាប្រាតិភោគ
- ង- ការជួញដូរមាសដែលមិនទាន់កែច្នៃជាគ្រឿងអលង្ការ។

៣- ពាក្យ "ថាមពលអគ្គិសនី" សំដៅដល់ ថាមពលអគ្គិសនី ដែលត្រូវបានផ្គត់ផ្គង់សម្រាប់ការប្រើប្រាស់ក្នុងជីវភាពរស់នៅឬការប្រកបអាជីវកម្ម។ ការផ្គត់ផ្គង់ថាមពលអគ្គិសនីមិនរាប់បញ្ចូលទេនូវការតបណ្តាញនិងឧបករណ៍វាស់ស្ទង់នានា។

៤- ពាក្យ “ទឹកស្អាត” សំដៅដល់ ទឹកស្អាត ដែលត្រូវបានផ្គត់ផ្គង់សម្រាប់ការប្រើប្រាស់ក្នុងជីវភាពរស់នៅឬការប្រកបអាជីវកម្ម វៀរលែងតែទឹកផលិតសម្រាប់ទទួលទានគ្រប់ប្រភេទ។ ការផ្គត់ផ្គង់ទឹកស្អាតមិនរាប់បញ្ចូលទេនូវការដាក់បំពង់បង្ហូរនិងឧបករណ៍វាស់ស្ទង់នានា។

៥- ពាក្យ “ផលិតផលកសិកម្មមិនទាន់កែច្នៃ” សំដៅដល់ ដើម សំបក ស្លឹក ផ្កា ផ្លែ គ្រាប់ ឫស មើម ឬជំរ នៃរុក្ខជាតិដែលបានមកពីការធ្វើកសិកម្មដាំដុះក្នុងស្រុក ទោះត្រូវបានឬមិនទាន់បានហាន់ឬកិនបំបែកក្ដី និងដែលមិនទាន់ត្រូវបានយកទៅកែច្នៃជាផលិតផលសម្រេច។

៦- ពាក្យ “កាកសំណល់រឹង-រាវ” សំដៅដល់ វត្ថុឬសារធាតុរឹង-រាវ ដែលលែងមានប្រយោជន៍ឬត្រូវបានឈប់ប្រើប្រាស់ឬតម្រូវឱ្យបោះបង់ចោល។

**ប្រការ ៥.- ការផ្គត់ផ្គង់ទំនិញឬសេវាដែលជាការផ្គត់ផ្គង់មិនជាប់អាករ**

ការផ្គត់ផ្គង់ទំនិញឬសេវាដូចខាងក្រោម គឺជាការផ្គត់ផ្គង់មិនជាប់អាករ÷

១- សេវាប្រៃសណីយ៍សាធារណៈ។

២- សេវារបស់មន្ទីរពេទ្យនិងគ្លីនិក សេវាខាងវេជ្ជសាស្ត្រនិងទន្តសាស្ត្រ និងការលក់ទំនិញបន្ទាប់បន្សំខាងវេជ្ជសាស្ត្រនិងទន្តសាស្ត្រដែលទាក់ទិននឹងការបំពេញសេវាទាំងនេះ។

៣- សេវាដឹកជញ្ជូនអ្នកដំណើរដោយប្រព័ន្ធដឹកជញ្ជូនសាធារណៈ ដែលជាកម្មសិទ្ធិទាំងស្រុងរបស់រដ្ឋ។

៤- សេវាធានារ៉ាប់រង។

៥- សេវាជាមូលដ្ឋានខាងហិរញ្ញវត្ថុ។

៦- ការនាំចូលសម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួនដែលរួចពន្ធគយស្របតាមបទប្បញ្ញត្តិស្ដីពីគយ។

៧- សកម្មភាពមិនស្វែងរកចំណេញដើម្បីបំរើផលប្រយោជន៍សាធារណៈ។

៨- សេវាសិក្សាអប់រំ។

៩- ថាមពលអគ្គិសនី និងទឹកស្អាត។

១០- ផលិតផលកសិកម្មមិនទាន់កែច្នៃ។

១១- សេវាប្រមូល ឬសម្អាតកាកសំណល់រឹង-រាវ។

**ប្រការ ៦.- ឥណទានអាករលើធាតុចូល**

ឥណទានអាករលើធាតុចូលលើការនាំចូល ឬការទិញក្នុងស្រុក នូវសម្ភារៈនិងវត្ថុធាតុដើមសម្រាប់ផលិតនិងផ្គត់ផ្គង់ទំនិញឬសេវា ដូចមានចែងក្នុងប្រការ៥ នៃប្រកាសនេះ ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃមាត្រា២៩ ដល់មាត្រា៤១ នៃអនុក្រឹត្យស្ដីពីអាករលើតម្លៃបន្ថែម។

**ប្រការ ៧.- ការអនុវត្ត**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

បណ្ឌិត. **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ ៧ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

លេខ ០៤៤៤/ ប.ក /២០១៧

## ប្រកាស
## ស្តីពី
## ការប្រើប្រាស់ឯកសណ្ឋាន ស្លាកសញ្ញា និងទង់ជ័យ កងយោធពលខេមរភូមិន្ទ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើ ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដាឆ្នាំ២០០១ ស្តីពីការ កែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំង របស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការ ប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ២៩អនក្រ.បក ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០០២ ស្តីពីបទវិន័យទូទៅ សម្រាប់កងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ៣១ អនក្រ.បក.ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការកែសម្រួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យ ក្រសួងការពារជាតិ មកជាអគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ១២ អនក្រ.បក ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីឯកសណ្ឋាន ស្លាកសញ្ញា និងទង់ជ័យ នៃកងយោធពលខេមរភូមិន្ទ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងការពារជាតិ

## សម្រេច

**ប្រការ១.-**

ប្រកាសនេះមានគោលបំណងកំណត់ពីការប្រើប្រាស់ឯកសណ្ឋាន ស្លាកសញ្ញា និងទង់ជ័យ កងយោធពលខេមរភូមិន្ទ។

វិថីហ្សកនីមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារ៖ ០២៣ ៨៨៣ ២៧៨ អ៊ីម៉ែល៖ generalsec@mod.gov.kh

**ប្រការ២.-**

ការប្រើប្រាស់ឯកសណ្ឋានគ្រប់ប្រភេទ និងស្លាកសញ្ញាកងយោធពលខេមរភូមិន្ទ ត្រូវបានកំណត់ដូចខាងក្រោម៖

**១- ឯកសណ្ឋានធំលេខ១**

- ឯកសណ្ឋាននេះសម្រាប់ចូលរួមព្រះរាជពិធីក្នុងព្រះបរមរាជវាំង និង ព្រះរាជពិធី ដូចជា ច្រត់ព្រះនង្គ័ល បុណ្យអុំទូក បុណ្យឯករាជ្យជាតិ និងព្រះរាជពិធីផ្សេងៗទៀត របស់ព្រះមហាក្សត្រ
- ការស្លៀកពាក់ឯកសណ្ឋាននេះមាន៖ ពាក់សក្តិស្មាមានផ្ទៃពណ៌លឿង ពាក់ខ្សែឥស្សរិយយសលើស្មាស្តាំកន្ទុយខ្សែថ្កក់ឡេវអាវទី២ ពាក់គ្រឿងឥស្សរិយយស មេដាយ និងពាក់ស្រោមដៃពណ៌ស។

**២- ឯកសណ្ឋានធំលេខ២**

- ឯកសណ្ឋាននេះសម្រាប់ចូលរួមពិធីការជាតិ និង អន្តរជាតិ បំពេញបេសកកម្ម និងសិក្សាក្រៅប្រទេស
- ការស្លៀកពាក់ឯកសណ្ឋាននេះមាន៖ ពាក់សក្តិស្មាផ្ទៃពណ៌ខ្មៅ កងរាជអាវុធហត្ថផ្ទៃពណ៌ខៀវ សញ្ញាថ្នាក់ឧត្តមសេនីយ៍ ឬសញ្ញាទ័ពជំនាញលើកអាវ ពាក់ខ្សែឥស្សរិយយស លើស្មាស្តាំកន្ទុយខ្សែថ្កក់ឡេវអាវទី១ (សម្រាប់តែក្នុងប្រទេស) លើហោប៉ៅអាវស្តាំ ពាក់ស្លាកឈ្មោះ លើស្លាកឈ្មោះពាក់សញ្ញាស្ថាប័ន ឬសញ្ញាប្រភេទទ័ព ឡេវហោប៉ៅអាវស្តាំបន្ទោងរូបហនុមាន លើហោប៉ៅអាវឆ្វេងពាក់គ្រឿងឥស្សរិយយស និង មេដាយ ឬ ក្បាលគ្រឿងឥស្សរិយយស និងក្បាលមេដាយ លើផ្ទៃហោប៉ៅអាវឆ្វេងពាក់សញ្ញាវគ្គសិក្សា ពាក់ស្រោមដៃពណ៌សតាមកម្មវិធី និង នៅដើមដៃអាវស្តាំពាក់ស្លាកកងយោធពលខេមរភូមិន្ទ ដោយឡែក កងទ័ពជើងទឹកពេលចេញបេសកកម្ម និង សិក្សាក្រៅប្រទេស ពាក់ឯកសណ្ឋានពណ៌ខ្មៅ។

**៣- ឯកសណ្ឋានលេខ៣**

- ឯកសណ្ឋាននេះ សម្រាប់ចូលរួមពិធីការជាតិ និង អន្តរជាតិ និងពិធីការ យោធាផ្សេងៗ ដូចជា ទទួលភ្ញៀវជាតិ អន្តរជាតិ សិក្ខាសាលា បើក-បិទវគ្គ បំពេញបេសកកម្ម និងសិក្សាក្រៅប្រទេស
- ការស្លៀកពាក់ឯកសណ្ឋាននេះមាន៖ ពាក់សក្តិស្មាផ្ទៃពណ៌ខ្មៅ កងរាជអាវុធហត្ថផ្ទៃពណ៌ខៀវ សញ្ញាថ្នាក់ឧត្តមសេនីយ៍ ឬសញ្ញាទ័ពជំនាញលើកអាវ លើហោប៉ៅអាវស្តាំពាក់ស្លាកឈ្មោះ លើស្លាកឈ្មោះពាក់សញ្ញាស្ថាប័ន ឬសញ្ញាប្រភេទទ័ព ឡេវហោប៉ៅអាវស្តាំបន្ទោងរូបហនុមាន លើហោប៉ៅអាវឆ្វេងពាក់ក្បាលគ្រឿងឥស្សរិយយស និង ក្បាលមេដាយ លើផ្ទៃហោប៉ៅអាវឆ្វេងពាក់សញ្ញាវគ្គសិក្សា និងនៅដើមដៃ អាវស្តាំ ពាក់ស្លាកសញ្ញាកងយោធពធខេមរភូមិន្ទ។

**៤- ឯកសណ្ឋានលេខ៤**

- ឯកសណ្ឋាននេះសម្រាប់ធ្វើការងារក្នុងការិយាល័យ ក្នុងបន្ទាយ និងទំនាក់ទំនងការងារ
- ការស្លៀកពាក់ឯកសណ្ឋាននេះមាន៖ ពាក់សក្តិស្មាផ្ទៃពណ៌ខ្មៅ កងរាជអាវុធហត្ថផ្ទៃពណ៌ខៀវ នៅកអាវពាក់សញ្ញាថ្នាក់ឧត្តមសេនីយ៍ ឬសញ្ញាទ័ពជំនាញ លើហោប៉ៅអាវស្តាំពាក់ស្លាកឈ្មោះ លើស្លាកឈ្មោះពាក់សញ្ញាស្ថាប័ន ឬសញ្ញាប្រភេទទ័ព នៅឡេវហោប៉ៅអាវស្តាំបន្ទោងរូបហនុមាន លើហោប៉ៅអាវឆ្វេងពាក់ក្បាលគ្រឿងឥស្សរិយយស និងក្បាលមេដាយ លើផ្ទៃហោប៉ៅអាវឆ្វេងពាក់ស្លាកសញ្ញាវគ្គសិក្សា នៅដើមដៃអាវស្តាំ ពាក់ស្លាកសញ្ញាកងយោធពលខេមរភូមិន្ទ និង ដើមដៃអាវឆ្វេងពាក់សញ្ញាកង ឯកភាព (បើមាន)

ដោយឡែកកងរាជអាវុធហត្ថ ទ័ពពិសេសឆ័ត្រយោង ទ័ពការពារព្រំដែន កងកម្លាំងរក្សាសន្តិភាព នាយទាហានទ័ពជើងទឹក នាយទាហានកម្មសិក្សា កម្លាំងពិសេសប្រឆាំងភេរវកម្ម ពាក់មួកបេរ៉េ ទ័ពអាកាសពាក់មួកបោនេឬបេរ៉េ និងពលនារី នាយនារីរងពាក់ឯកសណ្ឋានម៉ាតឺឡូ។

**៥- ឯកសណ្ឋានលេខ៥**

- ឯកសណ្ឋាននេះសម្រាប់ចេញប្រតិបត្តិការ ធ្វើការក្នុងបន្ទាយ ហ្វឹកហាត់ និងចូលរួមពិធីបើក និងបិទវគ្គតាមកម្មវិធីកំណត់
- ការស្លៀកពាក់ឯកសណ្ឋាននេះមាន៖ នៅកអាវខាងឆ្វេងពាក់សញ្ញាសក្តិផ្ទៃពណ៌ខ្មៅ កងរាជអាវុធហត្ថផ្ទៃពណ៌ខៀវ កអាវខាងស្តាំពាក់សញ្ញាថ្នាក់ឧត្តមសេនីយ៍ ឬទ័ពជំនាញ លើហោប៉ៅអាវស្តាំស្លាកឈ្មោះដេរភ្ជាប់ លើហោប៉ៅអាវឆ្វេងអក្សរខ.ភ.មដេរភ្ជាប់ នៅដើមដៃអាវស្តាំពាក់ស្លាកសញ្ញាកងយោធពលខេមរភូមិន្ទ នៅដើមដៃអាវឆ្វេងពាក់ ស្លាកសញ្ញាកងឯកភាព(បើមាន) ពាក់មួកបារ្យ៉ែកី បេរ៉េ ឬមួកដែក (តាមការកំណត់របស់កងឯកភាព)។

**៦-ឯកសណ្ឋានកម្មសិក្សានាយទាហាន**

- ឯកសណ្ឋាននេះ សម្រាប់កម្មសិក្សានាយទាហានដែលបានចូលវគ្គហ្វឹកហ្វឺនបណ្តុះបណ្តាលនាយទាហាន ចំពោះការប្រើឯកសណ្ឋាននេះត្រូវ អនុវត្តតាមការកំណត់របស់សាលា និងកម្មសិក្សា ឬនាយទាហានដែលបញ្ចប់ការហ្វឹកហ្វឺនខាងលើមិនអនុញ្ញាតឱ្យពាក់ឡើយ
- ការស្លៀកពាក់ឯកសណ្ឋាននេះមាន៖ ពាក់សក្តិកម្មសិក្សានៅលើស្មា លើហោប៉ៅអាវស្តាំពាក់ស្លាកឈ្មោះ នៅលើស្លាកឈ្មោះពាក់សញ្ញាស្ថាប័ន ឬប្រភេទទ័ព នៅឡេវអាវស្តាំបន្តោងរូបហនុមាន លើហោប៉ៅអាវឆ្វេងពាក់ក្បាលគ្រឿងឥស្សរិយយស និងមេដាយផ្ទៃហោប៉ៅអាវឆ្វេងពាក់សញ្ញាវគ្គសិក្សានៅដើមដៃអាវស្តាំពាក់ស្លាកសញ្ញា កងយោធពលខេមរភូមិន្ទ និងដើមដៃអាវឆ្វេងពាក់សញ្ញាកងឯកភាព(បើមាន)។

**៧-ឯកសណ្ឋានបច្ចេកទេស**

- ឯកសណ្ឋាននេះ សម្រាប់ធ្វើការងារបច្ចេកទេសគ្រឿងបំពាក់គ្រប់ប្រភេទ រោងជាង មន្ទីរពេទ្យ ឬគិលានុបដ្ឋានយោធានានា ហើយមិនអនុញ្ញាតឱ្យពាក់ឯកសណ្ឋាននេះពេលចប់ម៉ោងធ្វើការងារបច្ចេកទេស និង ជំនាញឡើយ
- ការស្លៀកពាក់ឯកសណ្ឋាននេះមាន៖ តែមួក អាវ ខោ ស្បែកជើងប៉ុណ្ណោះ គ្មានពាក់សញ្ញាសក្តិ និងសញ្ញាគួបផ្សំទាំងអស់ លើកលែងតែឯកសណ្ឋានអ្នកបើកយន្តហោះ នៅកអាវមានពាក់សក្តិ និងសញ្ញាជំនាញ និងដៃស្តាំពាក់សញ្ញាកងយោធពលខេមរភូមិន្ទនៅលើដៃអាវឆ្វេងពាក់ស្លាកសញ្ញាកងឯកភាព។

**៨-ឯកសណ្ឋានជំនាញកម្លាំងពិសេសប្រឆាំងភេរវកម្ម**

- ការស្លៀកពាក់ឯកសណ្ឋានធំលេខ១ លេខ២ លេខ៣ និងលេខ៤ ដូចកងទ័ពជើងគោក តែឯកសណ្ឋានលេខ៤ពាក់មួកប៉េរ៉េ និងឯកសណ្ឋានលេខ៥ នៅលើផ្ទៃហោប៉ៅអាវស្តាំមានស្លាកសញ្ញាសំគាល់កម្លាំងពិសេសប្រឆាំងភេរវកម្មពណ៌ខ្មៅ។

**៩-ឯកសណ្ឋានកងរាជអាវុធហត្ថ**

៩.១.ការស្លៀកពាក់ឯកសណ្ឋានធំលេខ១ លេខ២ លេខ៣ លេខ៤ និងលេខ៥ ដូចកងទ័ពជើងគោក។

៩.២. ឯកសណ្ឋានជំនាញ ប្រើសម្រាប់ប្រតិបត្តិការ និងធ្វើការក្នុងបន្ទាយ

ការស្លៀកពាក់ឯកសណ្ឋាននេះមាន៖ នៅលើកអាវពាក់សញ្ញាសក្តិ ( ដេរភ្ជាប់ ) លើហោប៉ៅអាវស្តាំដាក់ស្លាកឈ្មោះ ( ដេរភ្ជាប់ ) នៅលើស្លាកឈ្មោះមានសញ្ញាស្ថាប័ន ឬប្រភេទទ័ព នៅឡេវអាវស្តាំបន្តោងរូបហនុមាន លើហោប៉ៅអាវឆ្វេងពាក់សញ្ញា កងរាជ

អាវុធហត្ថធ្វើពីលោហធាតុ នៅដើមដៃអាវស្តាំពាក់ស្លាកសញ្ញាកងយោធពលខេមរភូមិន្ទ នៅលើស្មាខាងស្តាំពាក់ខ្សែកញ្ចែ នៅដើមដៃឆ្វេងពាក់ប៉ាន់ ដៃរបស់កងរាជអាវុធហត្ថ និង ពាក់ខ្សែប្រឹតែលពណ៌ស។

៩.៣.ឯកសណ្ឋានយានយន្តកិត្តិយសប្រើសម្រាប់ក្នុងពេលបំពេញបេសកកម្ម

ការស្លៀកពាក់ឯកសណ្ឋាននេះមាន៖ នៅលើស្មាពាក់ស្លាកសញ្ញាសក្តិផ្ទៃពណ៌ខៀវ នៅលើហោប៉ៅអាវស្តាំពាក់ស្លាកឈ្មោះ នៅលើស្លាកឈ្មោះពាក់ស្លាកសញ្ញាស្ថាប័ន ឬប្រភេទទ័ព នៅឡេវអាវស្តាំបន្តោងរូបហនុមាន នៅលើកអាវពាក់សញ្ញាទ័ពជំនាញ លើហោប៉ៅអាវឆ្វេងពាក់ស្លាកសញ្ញាកងរាជអាវុធហត្ថ ធ្វើពីលោហធាតុនៅលើស្មាស្តាំពាក់ខ្សែកញ្ចែ នៅដើមដៃអាវស្តាំពាក់ស្លាកសញ្ញាកងយោធពលខេមរភូមិន្ទ ពាក់កន្សែងរុំកពណ៌ខៀវ និងនៅចង្កេះពាក់ខ្សែក្រវ៉ាត់ធំ ដែលមានស្លាកសញ្ញាកងរាជអាវុធហត្ថពីក្រោយ។

**ប្រការ៣..**

ការរៀបចំកម្លាំងនិងការប្រើប្រាស់ឯកសណ្ឋានកងកិត្តិយសកងត្រែទ័ពត្រូវបានកំណត់ដូចខាងក្រោម៖

## ១.ការរៀបចំកម្លាំងកងកិត្តិយស កងត្រែទ័ព

១.១ កងកិត្តិយស និងកងត្រែទ័ពមានតួនាទីជាយោធិន សម្រាប់ពិធីបដិសណ្ឋារកិច្ចភ្ញៀវជាតិ និង អន្តរជាតិ តាមពិធីការរដ្ឋ និង យោធាព្រមទាំងពិធីនានា ដែលផ្តល់កិត្តិយសឱ្យមានការរៀបចំអាវុធគ្រាស

១.២ ការរៀបចំកងកិត្តិយស និងកងត្រែទ័ពត្រូវបានកំណត់តាមបណ្តាថ្នាក់ដូចខាងក្រោម៖

ក-ព្រះមហាក្សត្រ ប្រធានាធិបតី ប្រមុខរដ្ឋ

- កងកិត្តិយសបីប្រភេទទ័ព (ជើងគោក ជើងទឹក ជើងអាកាស) និងកងសាបក្នុងមួយប្រភេទទ័ពចំនួន៣៨នាក់ សរុប១៥២នាក់
- ក្រុមទង់ ៧នាក់
- ក្រុមត្រែទ័ព ៦១នាក់
- មេបញ្ជាការកងកិត្តិយសបំពាក់ ឬប្រើដាវ

ខ-ប្រធានព្រឹទ្ធសភា រដ្ឋសភា នាយករដ្ឋមន្ត្រី

- កងកិត្តិយសបីប្រភេទទ័ព(ជើងគោក ជើងទឹក ជើងអាកាស) ក្នុងមួយប្រភេទទ័ពចំនួន ៣៨នាក់ សរុប១១៤នាក់
- ក្រុមទង់៦នាក់
- ក្រុមត្រែទ័ព៤១នាក់
- មេបញ្ជាការកងកិត្តិយសបំពាក់ ឬប្រើដាវ

គ-រដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការ

- កងកិត្តិយសបីប្រភេទទ័ព (ជើងគោក ជើងទឹក ជើងអាកាស) ក្នុងមួយប្រភេទទ័ពចំនួន ២៦នាក់ សរុប៧៨នាក់
- ក្រុមទង់ ៣នាក់
- ក្រុមត្រែទ័ព ៣១នាក់
- មេបញ្ជាការកងកិត្តិយសពាក់ស្រោមកាំភ្លើងខ្លី

ឃ- ឯកអគ្គរាជទូត រដ្ឋទូត ចូលដាក់សារតាំង

- កងកិត្តិយសបីប្រភេទទ័ព(ជើងគោក ជើងទឹក ជើងអាកាស) ក្នុងមួយប្រភេទទ័ព

ចំនួន ២៦នាក់ សរុប៧៨នាក់
- ក្រុមទង់៦នាក់
- ក្រុមត្រែទ័ព៨១នាក់
- មេបញ្ជាការកងកិត្តិយសបំពាក់ឬប្រើដាវ

១.៣ មេបញ្ជាការប្រភេទទ័ព មេបញ្ជាការយោធភូមិភាគ មេបញ្ជាការកងពលធំ-តូច និងកងឯកភាព ត្រូវរៀបចំកម្លាំងកងកិត្តិយសត្រែទ័ពសម្រាប់បដិសណ្ឋារកិច្ចដូចខាងក្រោម៖

ក-មេបញ្ជាការប្រភេទទ័ព
- កងកិត្តិយសរបស់ប្រភេទទ័ព ឬកងឯកភាព ចំនួន ២៤នាក់
- ក្រុមទង់៣នាក់
- ក្រុមត្រែទ័ព ៣នាក់ (បើមាន)
- មេបញ្ជាការកងកិត្តិយសពាក់ស្រោមកាំភ្លើងខ្លី

ខ-ថ្នាក់មេបញ្ជាការយោធភូមិភាគ និងកងពលធំ-តូច
- កងកិត្តិយស ចំនួន១៨នាក់
- ក្រុមទង់៣នាក់
- ក្រុមត្រែទ័ព ៣នាក់ (បើមាន)
- មេបញ្ជាការកងកិត្តិយសពាក់ស្រោមកាំភ្លើងខ្លី

១.៤ ការរៀបចំរូបភាព កងកិត្តិយស និងកងត្រែទ័ព ចំពោះព្រះមហាក្សត្រ ប្រធានាធិបតី ប្រមុខរដ្ឋ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី ត្រូវរៀបចំជាបីជួរទទឹង ក្នុងករណីភូមិសាស្ត្រ ឬទីកន្លែងប្រារព្ធពិធីតូច ខ្លី ត្រូវរៀបចំទៅតាមសភាពជាក់ស្តែង។

## ២.ការប្រើប្រាស់ឯកសណ្ឋានកងកិត្តិយស និងកងត្រែទ័ព

- ឯកសណ្ឋានកងកិត្តិយស កងត្រែទ័ព សម្រាប់ពិធីបដិសណ្ឋារកិច្ច និង ពិធីនានារបស់ព្រះមហាក្សត្រ ប្រធានាធិបតី ប្រមុខរដ្ឋ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងអគ្គមេបញ្ជាការ
- ការស្លៀកពាក់កងត្រែទ័ព កងកិត្តិយសទាំងបីប្រភេទ(ជើងគោកអាវពណ៌ក្រហម ជើងទឹកអាវពណ៌ស ជើងអាកាសអាវពណ៌ខៀវ) និងកងសាបពណ៌ស នៅលើស្មាពាក់សញ្ញាសក្តិពណ៌មាស មានរឹមព័ទ្ធជុំវិញ នៅលើស្មាស្តាំពាក់ខ្សែឥស្សរិយយសកន្ទុយខ្សែថ្នក់ឡេវអាវទី២ នៅលើហោប៉ៅឆ្វេងពាក់គ្រឿងឥស្សរិយយស និងមេដាយ ពាក់ខ្សែក្រវ៉ាត់ធំពណ៌សពីលើអាវ ពាក់ស្បែកជើងពណ៌ខ្មៅត្រឹមក្បាលជង្គង់ ជើងខោស៊កក្នុងស្បែកជើង និងស្រោមដៃពណ៌ស។

## ៣.ឯកសណ្ឋានពិធីបុណ្យសព

- ឯកសណ្ឋាននេះ សម្រាប់ចូលរួមបុណ្យសព ក្នុងពិធីឈរអមសព រំកិលសព និងពិធីដង្ហែរសព
- ការស្លៀកពាក់ឯកសណ្ឋាននេះមាន៖ ពាក់សក្តិស្មាផ្ទៃពណ៌ខ្មៅ នៅលើស្មាស្តាំពាក់ខ្សែឥស្សរិយយស កន្ទុយខ្សែថ្នក់ឡេវអាវទី១ នៅលើហោប៉ៅស្តាំពាក់ស្លាកឈ្មោះ នៅខាងលើស្លាកឈ្មោះ ពាក់ស្លាកស្ថាប័ន ឬប្រភេទទ័ព នៅឡេវហោប៉ៅអាវស្តាំបន្តោងរូបហនុមាន អាវសឺមីពណ៌ស ក្រវ៉ាត់កពណ៌ខ្មៅ ពាក់ខ្សែក្រវ៉ាត់ធំពណ៌ខ្មៅពីលើអាវ ស្បែកជើងកវែងត្រឹមក្បាលជង្គង់ ជើងខោស៊កក្នុងស្បែកជើង និងស្រោមដៃពណ៌ស។

## ៤ .ឯកសណ្ឋានកងកិត្តិយស សម្រាប់បញ្ជាការដ្ឋានប្រភេទទ័ព និងកងរាជអាវុធហត្ថ

- ឯកសណ្ឋាននេះសម្រាប់ពិធីបដិសណ្ឋារកិច្ចថ្នាក់ដឹកនាំជាន់ខ្ពស់ ចូលរួមពិធីរបស់បញ្ជាការដ្ឋានប្រភេទទ័ព ជាម្ចាស់កម្មវិធី ឬជាអ្នករៀបចំ និង បដិសណ្ឋារកិច្ច មេបញ្ជា

ការប្រភេទទ័ពជាតិ និងអន្តរជាតិ

- ការស្លៀកពាក់ឯកសណ្ឋាននេះ យកឯកសណ្ឋានធំលេខ២ ជើងគោកពណ៌ត្រែអ៊ី ជើងទឹកពណ៌ស ជើងអាកាសពណ៌ខៀវទឹកប៊ិច កងរាជអាវុធហត្ថអាវពណ៌ប្រផេះ ខោពណ៌ត្រែអ៊ី ពាក់សញ្ញាគូបផ្សំផ្សេងៗដូចឯកសណ្ឋានលេខ២ ពាក់ ខ្សែឥស្សរិយយសនៅស្មាស្តាំ កន្ទុយខ្សែថ្នក់ឡេវទី១ ពាក់ស្រោមដៃពណ៌ស និង ពាក់ខ្សែក្រវ៉ាត់ធំពណ៌ខ្មៅពីលើអាវធំ។

**៥ .ឯកសណ្ឋានកងកិត្តិយសយោធភូមិភាគ កងពល និងអង្គភាពចំណុះ**

- ឯកសណ្ឋាននេះ សម្រាប់បដិសណ្ឋារកិច្ចថ្នាក់ដឹកនាំក្រសួងការពារជាតិ អគ្គមេបញ្ជាការ មេបញ្ជាការប្រភេទទ័ព មេបញ្ជាការយោធភូមិភាគ កងពលធំ តូច និងមេបញ្ជាការអង្គភាព ចូលរួមពិធីនានារបស់កងឯកភាពចំណុះ
- ការស្លៀកពាក់ឯកសណ្ឋានកងកិត្តិយសនេះគឺយកឯកសណ្ឋានលេខ៥ ពាក់មួកបេរ៉េក៏បូមួកដែក (ឱ្យឯកភាពគ្នា) ពាក់ស្រោមដៃពណ៌ស។

**ប្រការ៤...**

ការប្រើប្រាស់ស្លាកសញ្ញា និងបរិក្ខាររួមផ្សំរបស់កងយោធពលខេមរភូមិន្ទ ត្រូវបានកំណត់ដូចខាងក្រោម៖

**១ រូបព្រះសង្ហារ**

- រូបព្រះសង្ហារធ្វើពីលោហធាតុ សម្រាប់ពាក់លើមួកកាស្កេត និងមួកស៊ូកាស
- រូបព្រះសង្ហារធ្វើពីអំបោះ ( ប៉ាក់ ឬបោះពុម្ព ) សម្រាប់ពាក់លើមួកបេរ៉េក៏ បេរ៉េនិងមួកបោនេ។

**២ ស្លាកសញ្ញាកងយោធពលខេមរភូមិន្ទ**

- សម្រាប់ពាក់នៅលើដៃអាវស្តាំឯកសណ្ឋានលេខ២ លេខ៣ លេខ៤ និងលេខ៥។

**៣ ស្លាកសញ្ញារូបហនុមាន**

សម្រាប់បន្តោងនៅឡេវហោប៉ៅអាវស្តាំឯកសណ្ឋានលេខ២ លេខ៣ លេខ៤ ឯកសណ្ឋានប្រតិបត្តិការកងរាជអាវុធហត្ថ ឯកសណ្ឋានកម្មសិក្សា ឯកសណ្ឋានបុណ្យសព និងឯកសណ្ឋានកងយានយន្តកិត្តិយសកងរាជអាវុធហត្ថ។

**៤ ស្លាកឈ្មោះ និងស្លាកអក្សរ ខ.ភ.ម**

- ស្លាកឈ្មោះធ្វើពីជ័រប្លាស្ទិក សម្រាប់បំពាក់នៅលើហោប៉ៅអាវស្តាំ ឯកសណ្ឋានលេខ២ លេខ៣ លេខ៤ ឯកសណ្ឋានកម្មសិក្សា ឯកសណ្ឋានបុណ្យសព និងឯកសណ្ឋានកងយានយន្តកិត្តិយសកងរាជអាវុធហត្ថ
- ស្លាកឈ្មោះប៉ាក់ ឬបោះពុម្ពនៅលើក្រណាត់ សម្រាប់ពាក់លើហោប៉ៅអាវស្តាំ ឯកសណ្ឋានលេខ៥ ឯកសណ្ឋានប្រតិបត្តិការកងរាជអាវុធហត្ថ
- ស្លាកអក្សរខ.ភ.មប៉ាក់ឬបោះពុម្ពលើក្រណាត់សម្រាប់ពាក់នៅលើហោប៉ៅអាវឆ្វេង ឯកសណ្ឋានលេខ៥ របស់កងទ័ពជើងគោក ជើងទឹក ជើងអាកាស កងរាជអាវុធហត្ថ និងកម្លាំងពិសេសប្រឆាំងភេរវកម្ម។

**៥ សញ្ញាស្ថាប័នក្រសួងការពារជាតិ អគ្គបញ្ជាការដ្ឋាន និងបញ្ជាការដ្ឋានប្រភេទទ័ព**

- ធ្វើអំពីលោហធាតុសម្រាប់ពាក់នៅលើស្លាកឈ្មោះ លើហោប៉ៅអាវស្តាំឯកសណ្ឋានលេខ២ លេខ៣ លេខ៤ ឯកសណ្ឋានកម្មសិក្សា និងឯកសណ្ឋានយានយន្តកិត្តិយសកងរាជអាវុធហត្ថ និងសម្រាប់ដាក់លើហ្វុងក្នុងការិយាល័យធ្វើការ អគារទីបញ្ជាការ ក្លោងទ្វារ។ល។
- រូបសញ្ញានេះប្រើនៅលើក្បាលលិខិតផ្លូវការ និងបិទភ្ជាប់នៅលើយានយន្តនៃស្ថាប័ននិងប្រភេទទ័ព។

**៦ ស្លាកសញ្ញាកងឯកភាព**

- សម្រាប់ពាក់នៅលើដៃអាវឆ្វេងឯកសណ្ឋានលេខ៤ លេខ៥ ឯកសណ្ឋានកម្មសិក្សា លើយានយន្ត ក្លោងទ្វារ អគារទីបញ្ជាការ។

**៧ ស្លាកសញ្ញាថ្នាក់ឧត្តមសេនីយ៍ និងទ័ពជំនាញ**

- សម្រាប់ពាក់នៅលើកអាវ ឯកសណ្ឋានលេខ២ លេខ៣ លេខ៤ ឯកសណ្ឋានកម្មសិក្សា ឯកសណ្ឋានយានយន្តកិត្តិយសកងរាជអាវុធហត្ថ ធ្វើពីលោហធាតុ និង ប៉ាក់ឬបោះពុម្ពនៅកអាវឯកសណ្ឋានលេខ៥ ឯកសណ្ឋានប្រតិបត្តិការកងរាជអាវុធហត្ថ។

**៨ ស្លាកសញ្ញាកងរាជអាវុធហត្ថ**

- សម្រាប់ពាក់នៅលើហោប៉ៅអាវឆ្វេងធ្វើពីលោហធាតុ ឯកសណ្ឋានលេខ៤ ឯកសណ្ឋានប្រតិបត្តិការ ក្លោងទ្វារ អគារទីបញ្ជាការ និងយានយន្ត។

**ប្រការ៥.-**

ការប្រើប្រាស់ និងរក្សាទុកទង់ជ័យកងយោធពលខេមរភូមិន្ទ ត្រូវបានកំណត់ដូចខាងក្រោម៖

- ទង់ជ័យកងយោធពលខេមរភូមិន្ទ សម្រាប់ប្រើក្នុងការប្រារព្ធពិធីនានារបស់កងយោធពលខេមរភូមិន្ទជាតំណាងឱ្យអត្តសញ្ញាណរបស់កងឯកភាពនីមួយៗ
- ការរក្សាទុកទង់ជ័យកងឯកភាពនីមួយៗនៅទីកន្លែងមានកិត្តិយស និងមានសុវត្ថិភាព ដោយបញ្ឈរហាមទុកដោយបត់ឬផ្ដេក។

**ប្រការ៦.-**

យោធិននៃកងយោធពលខេមរភូមិន្ទត្រូវស្លៀកពាក់ឯកសណ្ឋានឱ្យបានត្រឹមត្រូវតាមប្រកាសនេះ។ មេបញ្ជាការកងឯកភាពនីមួយៗ ត្រូវកំណត់អំពីការស្លៀកពាក់ឯកសណ្ឋាន តាមពេលវេលា កន្លែងធ្វើការ ការហ្វឹកហាត់ និងក្នុងពិធីផ្សេងៗ សម្រាប់យោធិនក្នុងកងឯកភាពខ្លួនឱ្យបានឯកភាពគ្នា។

**ប្រការ៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៨.-**

អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ អគ្គលេខាធិការក្រសួងការពារជាតិ គ្រប់អគ្គនាយក នៃអគ្គនាយកដ្ឋាន នាយក នាយកដ្ឋាន ប្រធានស្ថាប័ន និងមេបញ្ជាការគ្រប់កងឯកភាពដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០១៧

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

នាយឧត្តមសេនីយ៍ ទៀ បាញ់

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងការពារជាតិ
- ដូចប្រការ៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

រក្សាសិទ្ធ និងបោះពុម្ពដោយ
អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
នៃ ទីស្ដីការគណៈរដ្ឋមន្ត្រី